**ប្ដំណឹង គួរឱ្យរំភើប ការធ្វើឱ្យប្រសើរឡើង កំពុងតែជិតមកដល!**

ជូនចំពោះអ្នកជំងឺមជ្ឈមណ្ឌលសុខភាពសហគមន៍ឡូវែល
យើងមានសេចក្ដីសោមនស្សរីករាយក្នុងការចែករំលែកព័ត៌មានធំ ៗ មួយចំនួនអំពីការកែលម្អដែលមកដល់មជ្ឈមណ្ឌលសុខភាពសហគមន៍ឡូវែល! ចាប់ពីថ្ងៃច័ន្ទ ទី 29 ខែមេសា តទៅ យើងនឹងចាប់ផ្ដើម កែប្រែឱ្យប្រសើរឡើងជាបន្តបន្ទាប់នៅជាន់ទី 1 របស់យើង ដែលរចនាឡើង ជាមួយ និងភាពងាយស្រួល និងការថែរទាំ ក្នុងចិត្តរបស់អ្នក។
ក្នុងរយៈពេល 6 ទៅ 7 ខែខាងមុខនេះ យើងនឹងធ្វើការ បង្កើត និងពង្រីក កន្លែងបន្ថែមទៀតសម្រាប់ការថែទាំអ្នកជំងឺ។ នេះរាប់




បញ្ចូលទាំងការផ្លាស់ប្ដូ មណ្ឌលអ្នកជំងឺដើរចូលរបស់យើង ជាមួយនឹងការបន្ថែមបន្ទប់ពិនិត្យថ្មីជាច្រើនទៀត ដែលយើងអាចមើលថែអ្នកដោយឯកជន និងប្រកបដោយផាសុកភាព ទីកន្លែងថ្មីដែលស្វាគមន៍ សម្រាប់អ្នករង់ចាំ និងតុស្វាគមន៍ថ្មីនៅជាន់ សំខាន់ខាងក្រោម របស់យើងដើម្បីធ្វើឱ្យអ្នក មកជួបពិនិត្យ ដោយរលូនតាមដែលអាចធ្វើទៅបាន។ បូករួមទាំងការអភិវឌ្ឍសំខាន់ៗផ្សេងទៀត ដើម្បីបម្រើអ្នកឱ្យកាន់តែប្រសើរឡើង។

ប្រសិនបើអ្នកមានអារម្មណ៍មិនស្រួលខ្លួន មណ្ឌលអ្នកជំងឺដើរចូលនឹងនៅតែបើកសម្រាប់ការពិនិត្យសុខភាពជូនអ្នកជំងឺ។ សូមអញ្ជើញមកមណ្ឌលអ្នកជំងឺដើរចូលដោយផ្ទាល់ ពុំចាំបាច់ទូរស័ព្ទមកមុននោះទេ។ សម្រាប់ការណាត់ជួបអ្នកជំងឺ ឈឺ ក្នុងថ្ងៃតែមួយសម្រាប់អ្នកជំងឺអាយុក្រោម 18 ឆ្នាំ សូមទូរស័ព្ទទៅលេខ 978.937.9700។ មជ្ឈមណ្ឌល Walk-In បើកពីថ្ងៃច័ន្ទដល់ថ្ងៃព្រហស្បតិ៍ចាប់ពីម៉ោង 8 ព្រឹកដល់ម៉ោង 7 យប់ថ្ងៃសុក្រពីម៉ោង 8 ព្រឹកដល់ម៉ោង 4 រសៀលថ្ងៃសៅរ៍ពីម៉ោង 9 ព្រឹកដល់ម៉ោង 1 រសៀលហើយបិទនៅថ្ងៃអាទិត្យ។ សូមប្រាកដថាក្នុងអំឡុងពេលនៃការផ្លាស់ប្ដូរទាំងនេះ ទ្វាររបស់យើងនៅតែបើកចំហ។ យើងប្ដេជ្ញារក្សា ផ្នែកទាំងអស់ បន្ត និងដំណើរការជាបន្តបន្ទាប់។

យើងសូមអភ័យទោសចំពោះភាពរអាក់រអួលណាមួយដែលការសាងសង់អាចបង្កឡើង និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្ររបស់អ្នក នៅពេលដែលយើងធ្វើការដើម្បីបង្កើនគ្រឿងបរិក្ខាររបស់យើងសម្រាប់អ្នក។
សូមអរគុណសម្រាប់ការជ្រើសរើសមជ្ឈមណ្ឌលសុខភាពសហគមន៍ឡូវែល។ យើងពិតជារំភើប ក្នុងការឃើញអ្នកទទួលបានបទពិសោធន៍ក្នុងការកែលម្អទាំងនេះ ឆាប់ៗ!
ដោយក្ដីគោរព,
ក្រុមមណ្ឌលសុខភាពសហគមន៍ឡូវែលរបស់អ្នក។